STATE OF CALIFORNIA
DMV
Department of Motor Vehicles

AB 60 ប្រើមគ្គុទ្ទេសក៍សម្រាប់ជម្រើសឯកសារងាយស្រួលដើម្បីទទួលបានប័ណ្ណបើកបររដ្ឋកាលីហ្វញ៉ា

អតិថិជនដាក់ពាក្យសុំប័ណ្ណបើកបរត្រូវតែផ្តល់នូវភស្តុតាងនៃអត្តសញ្ញាណ និង ការរស់នៅរដ្ឋកាលីហ្វញ៉ាប្រសិនបើពួកគេគ្មានភស្តុតាងនៃវត្តមានច្បាប់ជាទីពេញចិត្តទេ។ ប្រើសេចក្តីណែនាំខាងក្រោមដើម្បីជួយអ្នកកំណត់ឯកសារដែលត្រូវការនៅពេលដាក់ពាក្យសុំប័ណ្ណបើកបរ។

ភស្តុតាងនៃអត្តសញ្ញាណ៖

តារាង A

អ្នកដាក់ពាក្យត្រូវដាក់ឯកសារមួយ (1) ដូចខាងក្រោម។

ប័ណ្ណបើកបរ ឬអត្តសញ្ញាណប័ណ្ណរដ្ឋកាលីហ្វញ៉ា៖
- ប័ណ្ណបើកបររដ្ឋកាលីហ្វញ៉ា (ចេញ 10/2000 នៅ ឬបន្ទាប់ពី)
- អត្តសញ្ញាណប័ណ្ណរដ្ឋកាលីហ្វញ៉ា (ចេញ 10/2000 នៅ ឬបន្ទាប់ពី)

ឯកសារជាភាសបរទេសដែលគ្មានសុពលភាព និងមិនបានអនុម័តដោយក្រសួងយានយន្ត (*Department of Motor Vehicles,* DMV) និងពិនិត្យផ្ទៀងផ្ទាត់តាមអេឡិចត្រូនិកដោយ DMV ជាមួយនឹងប្រទេសនៃប្រភពដើម៖
- ប័ណ្ណបោះឆ្នោតសហព័ន្ធម៉ិកស៊ិក (Instituto Federal Electoral [IFE] Credencial para Votar – កំណែឆ្នាំ 2013)
- ប័ណ្ណបោះឆ្នោតជាតិនៃវិទ្យាស្ថានម៉ិកស៊ិក (Instituto Nacional Electoral [INE] Credencial para Votar – កំណែឆ្នាំ 2014)
- លិខិតឆ្លងដែនម៉ិកស៊ិក (បានចេញនៅក្នុងឆ្នាំ 2018 ឬក្រោយ និងរួមបញ្ចូលរូបថតឌីជីថល និងហត្ថលេខាឌីជីថល)
- ប័ណ្ណកុងស៊ុលម៉ិកស៊ិក (Matrícula Consular – កំណែឆ្នាំ 2014 ឬ 2022)

លិខិតឆ្លងដែនបរទេសដែលមានសុពលភាព និងអនុម័តដោយ DMV (សូមមើលទំព័រ 4&5 សម្រាប់បញ្ជីនៃលិខិតឆ្លងដែនដែលបានអនុម័ត)។ អតិថិជនក៏ត្រូវតែផ្តល់នូវលេខសន្តិសុខសង្គម (SSN) របស់គាត់ ដែលអាចផ្ទៀងផ្ទាត់បញ្ជាក់ជាអេឡិត្រូនិកជាមួយនឹងផ្នែកគ្រប់គ្រងសន្តិសុខសង្គម។

— ឬ —

តារាង B

អ្នកដាក់ពាក្យត្រូវដាក់ឯកសារចំនួនពីរ (2) ដូចខាងក្រោម។

ឯកសារជាភាសាបរទេសដែលមានសុពលភាព និងអនុម័តដោយ DMV៖
- អត្តសញ្ញាណប័ណ្ណអាស្សង់ទីន (Documento Nacional de Identidad [DNI] – កំណែឆ្នាំ 2009 ឬ 2012)
- ប័ណ្ណកុងស៊ុលប្រស៊ីល (Carteira de Matrícula Consular – កំណែឆ្នាំ 2010)
- អត្តសញ្ញាណប័ណ្ណឈីលី (Cédula de Identidad – កំណែឆ្នាំ 2013)
- ប័ណ្ណកុងកូឡុំប៊ី (Consular Registration – កំណែឆ្នាំ 2015)
- ឯកសារកំណត់អត្តសញ្ញាណកូឡុំប៊ី (Cédula de Ciudadanía – កំណែឆ្នាំ 2023)
- អត្តសញ្ញាណប័ណ្ណជាតិអេក្វាទ័រ (Cédula de Ciudadanía – កំណែឆ្នាំ 2006 និង 2009)
- ប័ណ្ណកុងស៊ុលអេក្វាទ័រ (Tarjeta de Identificación Consular – កំណែឆ្នាំ 2015)
- អត្តសញ្ញាណប័ណ្ណអ៊ែល សាវ៉ាដ័រ (Documento Único de Identidad [DUI] – កំណែឆ្នាំ 2010 ឬ 2022)
- អត្តសញ្ញាណប័ណ្ណជាតិ ហ្គាតេម៉ាឡាន (Documento Personal de Identificación [DPI] – កំណែឆ្នាំ 2012)
- ប័ណ្ណកុងស៊ុលហ្គាតេម៉ាឡាន (Tarjeta de Identificación Consular – កំណែឆ្នាំ 2002 និង 2015)
- ប័ណ្ណកុងស៊ុលហុងដូរ៉ាស (Gobierno de la República de Honduras Matrícula Consular – Consular ID – កំណែខែសីហា ឆ្នាំ 2017)
- អត្តសញ្ញាណប័ណ្ណកូរ៉េ (កំណែខែកញ្ញាឆ្នាំ 2016)
- អត្តសញ្ញាណប័ណ្ណជាតិនីហ្គារ៉ាហ្គ័រ (Cédula de Identidad – កំណែឆ្នាំ 2010)
- អត្តសញ្ញាណប័ណ្ណប៉ារ៉ាហ្គាយ (República del Paraguay Cédula de Identidad Civil – កំណែខែកញ្ញា ឆ្នាំ 2009)
- អត្តសញ្ញាណប័ណ្ណពេរ៉ូ (Documento Nacional de Identidad [DNI] – កំណែឆ្នាំ 2005)
- លិខិតឆ្លងបរទេស (សូមមើលទំព័រ 4&5 សម្រាប់បញ្ជីនៃលិខិតឆ្លងដែនដែលបានអនុម័តដោយ DMV) – នេះគឺជាជម្រើសមួយសម្រាប់អតិថិជនដែលមិនមាន SSN ដែលអាចពិនិត្យផ្ទៀងផ្ទាត់បាន ដូចដែលបានផ្តល់នៅក្នុងតារាង A។

— ឬ —

តារាង C ការត្រួតពិនិត្យមើលបន្ទាប់បន្សំ
អ្នកដាក់ពាក្យត្រូវដាក់ឯកសារខាងក្រោមឲ្យបានកាន់តែច្រើនកាន់តែល្អ ដែលនឹងត្រូវត្រួតពិនិត្យមើលដោយ DMV ដើម្បីពិនិត្យផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អ្នកដាក់ពាក្យ។
• ឯកសារសាលា រួមទាំងឯកសារដែលចេញដោយបឋមសិក្សា អនុវិទ្យាល័យ ឬស្ថាប័នក្រោយមធ្យមសិក្សា វិទ្យាល័យ ឬមហាវិទ្យាល័យរដ្ឋ ឬឯកជន ដែលរួមបញ្ចូលទាំងថ្ងៃខែឆ្នាំកំណើត ឬប្រសិនបើឯកសារសាលាជាភាសាបរទេស ត្រូវបានបិទការខ្ទង់ដោយសាលា និងរួមបញ្ចូលទាំងរូបថតរបស់អ្នកស្នើសុំនៅឆ្នាំដែលបានចេញកំណត់ត្រា។ • ឯកសារចេញដោយ ឬដាក់ជាមួយនឹងរដ្ឋាភិបាលនៅក្នុងសហរដ្ឋអាមេរិក (U.S.) ឬរដ្ឋាភិបាលអាមេរិក រួមមាន៖ — ទម្រង់ I-589 របស់ក្រសួងសន្តិសុខមាតុភូមិអាមេរិក (*Department of Homeland Security,* DHS) (ពាក្យស្នើសុំសម្រាប់អ្នកជ្រកកោនផ្នែកនយោបាយ និងសម្រាប់ដីកាតុលាការអន្តោប្រវេសន៍ដែលមិនឱ្យដល់ជនបរទេសចេញពីប្រទេស [*Application for Asylum and for Withholding of Removal*])។ — ទម្រង់ U.S. DHS Form I-20 (វិញ្ញាបនបត្រនៃលទ្ធភាពចូលសម្រាប់ស្ថានភាពសិស្សមិនអន្តោប្រវេសន៍ [F1] – សម្រាប់សិស្សសាលា និងសិស្សភាសា ឬវិញ្ញាបនបត្រនៃលទ្ធភាពចូលសម្រាប់ស្ថានភាពសិស្សមិនអន្តោប្រវេសន៍ [M-1] – សម្រាប់សិស្សផ្នែកវិជ្ជាជីវៈ)។ — ទម្រង់ U.S. DHS Form DS-2019 (វិញ្ញាបនបត្រនៃលទ្ធភាពចូលសម្រាប់ស្ថានភាពការផ្លាស់ប្តូរភ្ញៀវ [J-1]។ — ឯកសារតុលាការដែលមានបញ្ជាក់ថាអ្នកស្នើសុំមានឈ្មោះជាភាគគីមួយក្នុងចំណាត់ការតុលាការ។ — ប្រាក់ចំណូលនៃពន្ធលើប្រាក់ចំណូល — ប័ណ្ណបើកបរ • ឯកសារទាក់ទងនឹងស្ថានភាពនៃភាពនៅលីវឬរៀបការស៊ីវិល ឬស្ថានភាពរួមស៊ីវិល រួមទាំងសំបុត្រអាពាហ៍ពិពាហ៍ ឬការចុះបញ្ជីដៃគូរស់នៅជាមួយគ្នា។ ប្រសិនបើភាសានៅលើសំបុត្រអាពាហ៍ពិពាហ៍ជាភាសាផ្សេងពីអង់គ្លេស សំបុត្រអាពាហ៍ពិពាហ៍ត្រូវមានអមជាមួយនឹងការបកប្រែដែលមានការបញ្ជាក់ទទួលស្គាល់ឬសំបុត្របញ្ជាក់នៃការបកប្រែទៅជាភាសាអង់គ្លេស។ • ក្រឹត្យលែងលះ ប្រសិនបើភាសានៅលើក្រឹត្យជាភាសាផ្សេងពីអង់គ្លេស ក្រឹត្យត្រូវមានអមជាមួយនឹងការបកប្រែដែលមានការបញ្ជាក់ទទួលស្គាល់ ឬសំបុត្របញ្ជាក់នៃការបកប្រែទៅជាភាសាអង់គ្លេស។ • លិខិតដែនបរទេស អត្តសញ្ញាណប័ណ្ណកុងស៊ុល អត្តសញ្ញាណប័ណ្ណជាតិបរទេស ឬប័ណ្ណបើកបរបរទេស។ ប្រសិនបើប័ណ្ណបើកបរជាភាសាផ្សេងពីអង់គ្លេស ប័ណ្ណនោះត្រូវមានអមជាមួយនឹងការបកប្រែដែលមានការបញ្ជាក់ទទួលស្គាល់ ឬសំបុត្របញ្ជាក់នៃការបកប្រែទៅជាភាសាអង់គ្លេស។ • អត្តសញ្ញាណប័ណ្ណដែលមានរូបថតរបស់អ្នកស្នើសុំចេញដោយរដ្ឋាភិបាលនៅក្នុងសហរដ្ឋអាមេរិក (U.S.) ឬរដ្ឋាភិបាលអាមេរិក។ • ឯកសារបញ្ជាក់កំណើត រួមមានសំបុត្រកំណើត ឬកំណត់ត្រាសុំកូនចិញ្ចឹម។ • ឯកសារណាមួយខាងលើដែលមានកត់ត្រាប្តីឬប្រពន្ធរបស់អ្នកស្នើសុំ ដៃគូរស់នៅជាមួយគ្នា កូន ឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់ ដែលផ្តល់ដោយអ្នកស្នើសុំក៏ត្រូវផ្តល់សំបុត្រកំណើត កំណត់ត្រាសុំកូនចិញ្ចឹម សំបុត្រអាពាហ៍ពិពាហ៍ ឬការចុះបញ្ជីដៃគូរស់នៅជាមួយគ្នាដើម្បីតាមដានទំនាក់ទំនងផងដែរ។

— និង —

ភស្តុតាងនៃការរស់នៅរដ្ឋកាលីហ្វញ៉ា

តារាង D
អ្នកដាក់ពាក្យត្រូវដាក់ឯកសារមួយ (1) ដូចខាងក្រោម។ ឯកសារស្នាក់នៅទាំងអស់ត្រូវតែរាយនាម និងគោត្តនាមរបស់អ្នកស្នើសុំ ហើយអាសយដ្ឋានរស់នៅរដ្ឋកាលីហ្វញ៉ាត្រូវតែត្រូវគ្នាជាមួយនឹងអាសយដ្ឋានផ្ទើសំបុត្រដែលវ៉ាយនៅលើពាក្យ-ស្នើសុំប័ណ្ណបើកបរជាមួយនឹងការលើកលែងធាតុបី (3) ខាងក្រោម។
• កិច្ចព្រមព្រៀងជួលជាមួយហត្ថលេខារបស់ម្ចាស់/ម្ចាស់ដី និងអ្នកជួល/អ្នករស់នៅ។ • ប័ណ្ណកម្មសិទ្ធិ ឬសំបុត្រកាន់កាប់អចលនទ្រព្យរស់នៅពិត។ • វិក្កយបត្របញ្ជាំទ្រព្យ។ • វិក្កយបត្រទឹកភ្លើងនៅផ្ទះ (រួមទាំង វិក្កយបត្រទូរស័ព្ទដៃ)។ • ឯកសារសាលា។ • ឯកសារវេជ្ជសាស្ត្រ។ • ឯកសារការងារ។ • ឯកសារសាសនា • ឯកសារធានារ៉ាប់រង រួមទាំងវេជ្ជសាស្ត្រ ធ្មេញ ចក្ខុវិស័យ ជីវិត ផ្ទះ ជួល និងយានយន្ត។ • សេវាប្រាក់ចំណូលខាងក្នុង ឬប្រាក់ទទួលបានពីពន្ធនៃ *California Franchise Tax Board*។ • វិញ្ញាបនបត្រយានយន្តរដ្ឋកាលីហ្វញ៉ា ឬ សំបុត្រកាន់កាប់នាវា ឬការចុះបញ្ជី។ • ប័ណ្ណបើកបរ ឬអត្តសញ្ញាណប័ណ្ណរដ្ឋកាលីហ្វញ៉ា។ • ការផ្លាស់ប្តូរនៃការបញ្ជាក់អាសយដ្ឋានដោយសេវាកម្មប្រៃសណីយ៍សហរដ្ឋអាមេរិក (ទម្រង់ CNL 107)។ • ឯកសារដែលចេញដោយរដ្ឋាភិបាលនៅក្នុងសហរដ្ឋអាមេរិក (U.S.) ឬរដ្ឋាភិបាលអាមេរិក។ • វិក្កយបត្រលើពន្ធ ឬសេចក្តីថ្លែងនៃអចលនទ្រព្យ • កំណត់ត្រានៃស្តាប់នហិរញ្ញវត្ថុ។ • ទម្រង់ (*No Fee Identification Card Eligibility Verification,* DL 933) នៃការពិនិត្យផ្ទៀងផ្ទាត់សិទ្ធិទទួលអត្តសញ្ញាណប័ណ្ណដោយមិនគិតថ្លៃដែលអាចទទួលយកបាន។ ឯកសារខាងក្រោមមិនត្រូវការមានអាសយដ្ឋានផ្ទើសំបុត្ររដ្ឋកាលីហ្វញ៉ារបស់អតិថិជន៖ • ឯកសារតុលាការដែលរាយអ្នកស្នើសុំជាពលរដ្ឋនៃរដ្ឋការលីហ្វញ៉ា។ • លិខិតមួយ នៅលើក្បាលលិខិតពីផ្ទះសម្បែងទីជំរកជំរកមួយសម្រាប់ស្ត្រីដែលត្រូវបានរំលោភ អង្គភាពមិនរកប្រាក់កម្រៃ អង្គភាពផ្អែកលើការពិតនយោជក ឬរដ្ឋាភិបាលក្នុងសហរដ្ឋអាមេរិក ដែលបញ្ជាក់ថា អ្នកស្នើសុំដែលរស់នៅក្នុងរដ្ឋកាលីហ្វញ៉ា។ • ឪពុកម្តាយ អាណាព្យាបាលស្របច្បាប់ ឬកុមារអាចប្រើប្រាស់សំបុត្រកំណើតបាន ហើយប្តី/ប្រពន្ធ ឬដៃគូរស់នៅជាមួយគ្នាអាចប្រើប្រាស់សំបុត្រអាពាហ៍ពិពាហ៍ ឬវិញ្ញាបនបត្រចុះបញ្ជីដៃគូរស់នៅជាមួយគ្នាដើម្បីតាមដានទំនាក់ទំនងរបស់គាត់ជាមួយបុគ្គលដែលឯកសាររស់នៅខាងលើត្រូវបានរបស់គេត្រូវបានចុះអាសយដ្ឋាន។

លិខិតឆ្លងបរទេសដែលបានអនុម័ត

សម្គាល់៖ លិខិតឆ្លងដែនដែលបានអនុម័តបានរាយខាងក្រោមត្រូវតែប្រើជាមួយឯកសារដែលរាយនៅលើទំព័រទី 1។

ប្រសិនបើលិខិតឆ្លងប្រទេសមួយមិនបានរាយខាងក្រោម អ្នកអាចនៅតែដាក់ពាក្យសុំប័ណ្ណបើកបរ CA ក្រោមដំណើរការត្រួតពិនិត្យបន្ទាប់បន្សំ របស់ការស្នើបង្កើត។ សូមមើលទំព័រទី2 សម្រាប់ព័ត៌មាននៅក្នុងបញ្ជីនៃឯកសារទទួលយក។ សម្រាប់ព័ត៌មានបន្ថែមអំពីដំណើរការនេះ សូមយោងទៅលើខិត្តប័ណ្ណព័ត៌មាននៃដំណើរការត្រួតពិនិត្យបន្ទាប់បន្សំ #3 (*Driver License Secondary Review Referral Process,* FFDL3)។ **dmv.ca.gov/portal/dmv/detail/pubs/brochures/fast_facts/ffdl03**.

ឈ្មោះប្រទេស	បានចេញនៅ / នៅ ឬបន្ទាប់ពី
អាហ្ការហ្គានី	2011
អាល់បានី	2009
អាស្សង់ទីន	2009
អាមេនី	2011
អូស្ត្រាលី	2005
អូទ្រីស	2006
អាហ្ស៊ីបៃហ្សង់	2013
បាហាម៉ាស	2010
បារ៉ែន	2011
បង់ក្লាដែស	2010
បេឡារុស	2006
ប៊ែលហ្ស៊ិក	2006
បេលី	2005
ប៊ូលីវី	2010
ប៊ូស្នី និងហឺហ្ស៊ីហ្គូវីណា	2009
បុតស្វាណា	2010
ប្រេស៊ីល	2006
ប្រ៊ុយណេ	2008
ប៊ុលហ្គារី	2010
ប៊ីគីណាហ្វាសូ	2008
កាប៊ូ វ៉ីដ	2005
កម្ពុជា	2005
កាណាដា	2010
កោះខេមិន	2008
ឈីលី	2013

ឈ្មោះប្រទេស	បានចេញនៅ / នៅ ឬបន្ទាប់ពី
ប្រទេសចិន	2007
កូឡុំប៊ី	10/2009
កូម៉ូរ៉ូស	2008
កុងហ្គោ	2008
សាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ	2009
កូស្តារីកា	2006
កូឌីវ័រ	2008
ក្រូអាត	2009
ស៊ីព្រឹស	2010
សាធារណៈរដ្ឋឆែក	2005
ដាណឺម៉ាក	2012
សាធារណៈរដ្ឋដូមីនី	2006
អេក្វាឌ័រ	05/07/13
អេហ្ស៊ីប	2008
អែលសាវ៉ាឌ័រ	2009
អេក្វាទ័រ ហ្គីណេ	2011
អេរីទ្រា	2010
អេស្តូនី	2005
កោះហ្វ៊ីជី	2012
សាធារណរដ្ឋហ្វ៊ីជី	2018
ហ្ការ៉ាំងឡង់	2006
ប៉ារ៉ាំង	2006
ហ្គាបុង	2009
ហ្សកហ្ស៊ី	2005
អាល្លឺម៉ង់	2007

ឈ្មោះប្រទេស	បានចេញនៅ / នៅ ឬបន្ទាប់ពី
ហ្គាណា	2010
ក្រិក	2006
ហ្គោតេម៉ាឡា	2011
ហ្គីណេ-ប៊ីសូ	2008
ហុងដូរ៉ាស	2005
ហុងកុង	2006
ហុងគ្រី	2006
អ៊ីស្លង់	2006
ឥណ្ឌា	2008
ឥណ្ឌូនេស៊ី	2006
អន្តរប៉ូល។	2009
អ៊ីរ៉ង	2011
អ៊ីរ៉াক់	2009
អៀកឡង់	2006
អ៊ីស្រាអែល	2011
អ៊ីតាលី	2006
ចាម៉ៃកា	2009
ជប៉ុន	2006
កាហ្សាក់ស្ថាន	2009
កេនយ៉ា	2008
កូសូវ៉ូ	2008
ឡាតវី	2007
លីប៊ី	2009
លីទុយអានី	2006
លុចសំបូ	2006
ម៉ាការ	2009
ម៉ាសេដូនី FYR	2008
ម៉ាដាហ្គាস្ការ	2007
ម៉ាឡេស៊ី	2010

ឈ្មោះប្រទេស	បានចេញនៅ / នៅ ឬបន្ទាប់ពី
ម៉ាល់តា	2008
ម៉ិកស៊ិក	2008
ម៉ុងហ្គោលី	2011
ម៉ុងតេណេហ្គ្រូ	2008
ម៉ារ៉ុក	2009
ម៉ូហ្សំប៊ិក	2010
មីយ៉ាន់ម៉ា	2010
នេប៉াল់	2010
ហូឡង់	2006
ណូវែហ្ស៊ីឡង់	2009
នីការ៉াហ្គ	2010
នីហ្សេរីយ៉ា	2007
ន័រវែស	2005
ប៉াគីস্তান	06/2005
ប៉ាឡូ	2008
ដែនដីប៉ាឡេស្ទីន ដែលកាន់កាប់	2008
ប៉ាណាម៉া	2010
ប៉ារ៉াហ្គាយ	2012
ពេរ៉ូ	2010
ហ្វីលីពីន	2010
ប៉ូឡូញ	2006
ព័រទុយហ្គាល់	2006
កាតា	2008
សាធារណៈរដ្ឋកូរ៉	2008
រូម៉ានី	2008
រុស្ស៊ី	2010
សាំង ហេលេណা	2012
សាំងគីត និងណេវីស	2010
សានម៉ារីណូ	2009

ឈ្មោះប្រទេស	បានចេញនៅ / នៅ ឬបន្ទាប់ពី
សាវតូមេ និងព្រីនស៊ីប	2008
សេនេហ្គាល់	2008
សៃប៊ីរ	2008
សៀរ៉ាឡេអូន	2010
ស្លូវ៉ាគី	2005
ស្លូវេនី	2006
សូម៉ាលី	2007
អាហ្វ្រិកខាងត្បូង	2009
ស៊ូដង់ខាងត្បូង	2012
អេស្پ៉ាញ	2006
ស្រីលង្កា	1/2008
ស៊ីយអ៊ែត	2005
ស្វ៊ីស	2006
តៃវ៉ាន់	12/29/2008
តាហ្ស៊ីគីស្ថាន	2010
ថៃ	2009
តុងហ្គាន	07/2003
តួកគី	2010
ធឺកមែននីស្ថាន	2008
អ៊ីយក្រែន	2007
អារ៉ាប់រួម អ៊ីមីរ៉ាត	2011
ចក្រភពអង់គ្លេស	2006
អ៊ីយរ៉ាហ្គាយ	2009
វ៉ានូអាទូ	2010
ទីក្រុងវ៉ាទីកង់	2008
កោះវីជិន (ចក្រភពអង់គ្លេស)	2007
ហ្ស៊ីប៊ី	2008

សម្គាល់៖ សូមចំណាំថា ឯកសារនេះគឺស្ថិតក្រោមការផ្លាស់ប្តូរ